# សុន្ទរកថាស្វាគមន៍
# របស់ អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន, ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានក្រុមប្រឹក្សាជាតិ
# គាំពារសង្គម
# ថ្លែងក្នុងពិធី «បើកសប្តាហ៍គាំពារសង្គមកម្ពុជា ឆ្នាំ២០២៥ និង ប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ នូវ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ ២០២៤-២០៣៥ »

រាជធានីភ្នំពេញ, ថ្ងៃ ព្រហស្បតិ៍ ៨ រោច, ខែ មាឃ, ឆ្នាំ រោង, ឆស័ក ព.ស. ២៥៦៨
ត្រូវនឹងថ្ងៃទី ២០ ខែ កុម្ភៈ គ.ស. ២០២៥, នៅសណ្ឋាគារស៊ើហ្វីងសុខា ភ្នំពេញ

*****+*****

- សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត;
- ឯកឧត្តម, លោកជំទាវ, សមាជិក-សមាជិកានៃព្រឹទ្ធសភា, រដ្ឋសភា និង រាជរដ្ឋាភិបាល;
- ឯកឧត្តម, លោកជំទាវ, ឯកអគ្គរាជទូត, ឯកអគ្គរដ្ឋទូត, តំណាងដៃគូអភិវឌ្ឍន៍;
- ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, ជាទីមេត្រី!

ជាកិច្ចចាប់ផ្តើម, ក្នុងនាមក្រុមប្រឹក្សាជាតិគាំពារសង្គម និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់, ខ្ញុំសូមគោរពសម្តែងនូវគារវកិច្ចស្វាគមន៍ និង អំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះវត្តមានដ៏ឧត្តុងឧត្តមរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានឆ្លៀតពេលដ៏មមាញឹក, អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់, ក្នុងពិធី «**បើកសប្តាហ៍គាំពារសង្គមកម្ពុជា ឆ្នាំ២០២៥ និង ប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ នូវ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ ២០២៤-២០៣៥** »ដ៏មហោឡារិក នាថ្ងៃនេះ ។

ខ្ញុំក៏សូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ ជូន ឯកឧត្តម, លោកជំទាវ, សមាជិក-សមាជិកាព្រឹទ្ធសភា, រដ្ឋសភា និង រាជរដ្ឋាភិបាល, ព្រមទាំងឯកអគ្គរាជទូត-ឯកអគ្គរដ្ឋទូត, តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ, អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត, និង ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ ដែលបានអញ្ជើញចូលរួមក្នុងពិធីនេះ, ទាំងនៅទីនេះផ្ទាល់ និង តាមប្រព័ន្ធអនឡាញ ។

- សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី, ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត;
- អង្គពិធីទាំងមូល ជាទីមេត្រី!

ចាប់តាំងពីឆ្នាំ ២០២២ មក, ក្រុមប្រឹក្សាជាតិគាំពារសង្គម បានរៀបចំ **សប្តាហ៍គាំពារសង្គមកម្ពុជា** ជារៀងរាល់ឆ្នាំ ។ **សប្តាហ៍គាំពារសង្គម** គឺជាវេទិកាមួយដែលផ្តល់ឱកាសដល់ភាគីពាក់ព័ន្ធ ដើម្បីពិភាក្សា និង ផ្លាស់ប្តូរទស្សនវិស័យ, គោលនយោបាយ, ចែករំលែកចំណេះដឹង, បទពិសោធ, និង ឧត្តមានុវត្តន៍នៃគោលនយោបាយគាំពារសង្គម ពីប្រទេសផ្សេងៗ, ទាំងក្នុងតំបន់ និង លើសកលលោក, ជាពិសេស ដើម្បីផ្សព្វផ្សាយពីវឌ្ឍនភាពនៃប្រព័ន្ធគាំពារសង្គមកម្ពុជា ដល់អ្នកទទួលផល និង សាធារណជន ឲ្យបានជ្រាបកាន់តែច្បាស់ ។

សម្រាប់ ឆ្នាំ ២០២៥ នេះ យើងទាំងអស់គ្នា ពិតជាមានកិត្តិយស និង មោទកភាពបំផុតដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ផ្តល់កិត្តិយសអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធី «**បើកសប្តាហ៍គាំពារសង្គមកម្ពុជា ឆ្នាំ ២០២៥ និង ប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ នូវ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ ២០២៤-២០៣៥**» ដ៏មហោឡារិកនេះ ។ **ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម** ដំណាក់កាលថ្មីនេះ បានផ្លាស់ប្តូរអភិក្រមនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ពីប្រព័ន្ធដែលគាំពារតាមបែបសសរស្តម្ភ មកជាប្រព័ន្ធដែលគាំពារតាមហានិភ័យនៃវដ្តជីវិត (Life-cycle risk approach), ពោលគឺ ផ្តល់ការគាំពារជូនពលរដ្ឋ ចាប់តាំងពីពេលចាប់កំណើតដំបូងនៅក្នុងផ្ទៃម្តាយ រហូតដល់ដំណាក់កាលចុងក្រោយនៃវដ្តជីវិតរបស់គាត់ ។

**សប្តាហ៍គាំពារសង្គមកម្ពុជា ឆ្នាំ ២០២៥** ដែលមានរយៈពេលពីរថ្ងៃនេះ ត្រូវបានរៀបចំឡើងក្រោមមូលបទ **អភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា ដើម្បីការគ្របដណ្តប់កាន់តែប្រសើរ ទៅតាមហានិភ័យនៃវដ្តជីវិត** និង អមដោយការធ្វើបទបង្ហាញគន្លឹះ, កិច្ចពិភាក្សាពេញអង្គ, កិច្ចពិភាក្សាតាមក្រុម, និង ការប្រកួតតស៊ូមតិរបស់យុវជន លើប្រធានបទពាក់ព័ន្ធ ដោយមានការចូលរួមពី

គណៈអធិបតី, ភ្ញៀវកិត្តិយស ជាថ្នាក់ដឹកនាំក្រសួង-ស្ថាប័នពាក់ព័ន្ធ, អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត, ឯកអគ្គរាជទូត-ឯកអគ្គរដ្ឋទូត, តំណាងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ, តំណាងស្ថាប័នស្រាវជ្រាវ, សិស្ស-និស្សិត និង អ្នកទទួលផល, សរុបចំនួនប្រមាណ **១ ០០០ នាក់,** ទាំងអ្នកចូលរួមដោយផ្ទាល់នៅទីនេះ និង អ្នកចូលរួមតាមរយៈប្រព័ន្ធប្រជុំអនឡាញ ។

- **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី, ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត;**
- **អង្គពិធីទាំងមូល ជាទីមេត្រី!**

ខ្ញុំសូមអនុញ្ញាតយកឱកាសដ៏វិសេសនេះ គោរពរាយការណ៍ ជូន **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** និង អង្គពិធីទាំងមូល មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ អំពីវឌ្ឍនភាព និង សមិទ្ធផលសំខាន់ៗ នៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា ក្នុងដំណាក់កាលនៃការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ដោយចែកជា ២ ផ្នែក គឺៈ ១). ការកសាងប្រព័ន្ធ, និង ២). ការដាក់ចេញ និង ការពង្រីកវិសាលភាពនៃប្រព័ន្ធគាំពារសង្គម រួមបញ្ចូលនូវកម្មវិធីជាតិជំនួយសង្គម, របបសន្តិសុខសង្គម, និង អន្តរាគមន៍ឆ្លើយតបនឹងគ្រោះអាសន្ន ។

## ផ្នែកទី ១ : ការកសាងប្រព័ន្ធ

ដើម្បីកសាងប្រព័ន្ធគាំពារសង្គមដែលមានលក្ខណៈរឹងមាំ, មានភាពធន់ និង មានប្រសិទ្ធភាព, រាជរដ្ឋាភិបាល បានរៀបចំ និង ដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត, ឯកសារក្របខណ្ឌ, ផែនទីបង្ហាញផ្លូវ, យុទ្ធសាស្ត្រ, និង គោលការណ៍ណែនាំសំខាន់ៗ សម្រាប់ធ្វើស្ថាប័នូបនីយកម្ម, ក៏ដូចជា សម្រាប់ការជំរុញការអនុវត្តកម្មវិធីជាតិជំនួយសង្គម និង របបសន្តិសុខសង្គមនានា ជាបន្តបន្ទាប់ ។ ជាមួយគ្នានេះ, យន្តការស្ថាប័នក្នុងប្រព័ន្ធគាំពារសង្គម ក៏ត្រូវបានកែទម្រង់, ពង្រឹង និង ពង្រីកមុខងារ ដើម្បីធានាដល់ការចាត់ចែង និង ការគ្រប់គ្រងកម្មវិធីជាតិជំនួយសង្គម និង របបសន្តិសុខសង្គម, ជាពិសេស ការផ្តល់អត្ថប្រយោជន៍ដល់ពលរដ្ឋគោលដៅ ប្រកបដោយប្រសិទ្ធភាព, តម្លាភាព និង គណនេយ្យភាព ។

បន្ថែមលើនេះ, រាជរដ្ឋាភិបាលក៏បានរៀបចំបង្កើត និង ដាក់ឲ្យដំណើរការប្រព័ន្ធគាំពារសង្គមឌីជីថល ដើម្បីបង្កើនប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព និង សម្រួលដល់ប្រតិបត្តិការកម្មវិធី និង របបនានា ក្នុងប្រព័ន្ធគាំពារសង្គម ក៏ដូចជា រៀបចំ និង អនុវត្តយន្តការតាមដាន និង វាយតម្លៃ

ដើម្បីត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្ត និង ធ្វើការកែសម្រួលឲ្យបានទាន់ពេល, ដែលកិច្ចការនេះត្រូវបានរាជរដ្ឋាភិបាល សម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា ចាត់ទុកជាការងារដ៏សំខាន់ ក្នុងការវាស់វែងប្រសិទ្ធភាព និង លទ្ធផល នៃគោលនយោបាយដែលត្រូវបានដាក់ចេញ ។

ការកសាងប្រព័ន្ធនេះ បានផ្តល់មូលដ្ឋានគ្រឹះរឹងមាំ និង បានដើរតួជាកាតាលិករដ៏សំខាន់ ក្នុងការដាក់ចេញ និង ការពង្រីកវិសាលភាពប្រព័ន្ធគាំពារសង្គមជាបន្តបន្ទាប់ ដែលទទួលបានការសាទរពីសាធារណជន, នាពេលកន្លងទៅ, ដោយឈរលើអភិក្រម **«ពង្រឹងប្រព័ន្ធដើម្បីពង្រីកការគ្របដណ្តប់»** ។

## ផ្នែកទី ២ : ការដាក់ចេញ និង ការពង្រីកវិសាលភាពនៃប្រព័ន្ធគាំពារសង្គម

គិតចាប់តាំងពីឆ្នាំ ២០១៧ មក, រាជរដ្ឋាភិបាលបានសម្រេចសមិទ្ធផលជាច្រើន លើការអនុវត្ត និង ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ដើម្បីផ្តល់ការគាំពារដល់ពលរដ្ឋ តាមរយៈការពង្រីកវិសាលភាពកម្មវិធីជាតិជំនួយសង្គម និង របបសន្តិសុខសង្គម ដែលមានស្រាប់ និង ការដាក់ចេញនូវកម្មវិធីជាតិជំនួយសង្គម និង របបសន្តិសុខសង្គមថ្មីៗ ជាបន្តបន្ទាប់ ក្នុងទិដ្ឋភាពចំនួន ២ រួមមាន៖

### ១. ទិដ្ឋភាពជំនួយសង្គម៖

គិតត្រឹមដំណាច់ឆ្នាំ ២០២៤, កម្មវិធីជាតិជំនួយសង្គម មានចំនួន ៨ ដែលគ្របដណ្តប់លើពលរដ្ឋសរុបចំនួន **១,២ លានគ្រួសារ** ដែលមានសមាជិកចំនួនជាង **៤,៨ លាននាក់** (ស្មើនឹងប្រមាណ ២៨% នៃពលរដ្ឋសរុប) ដោយបានចំណាយថវិការដ្ឋ ក្នុងទំហំ **១ ១៤០ ប៊ីលានរៀល**, សមមូលប្រមាណ **២៨៥ លានដុល្លារអាម៉េរិក,** សម្រាប់ឆ្នាំ ២០២៤, ក្នុងនោះ រាជរដ្ឋាភិបាលបានពង្រីកវិសាលភាពកម្មវិធីជំនួយសង្គមដែលមានស្រាប់ រួមទាំងមូលនិធិសមធម៌សុខាភិបាលដល់ក្រុមគោលដៅ ដែលជាជនងាយរងគ្រោះ និង គ្រួសារងាយរងហានិភ័យ ក៏ដូចជា បានដាក់ឲ្យដំណើរការនូវកម្មវិធីថ្មីៗ ដូចជា កម្មវិធីជំនួយសង្គមផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈ និង កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដើម្បីបន្តជួយគាំទ្រជីវភាពគ្រួសារគោលដៅ និង ផ្តល់ឱកាសឲ្យពួកគាត់ អាចស្ថិតលើគន្លងនៃការចាកចេញពីភាពក្រីក្រ ។

## ២. ទិដ្ឋភាពសន្តិសុខសង្គម៖

គិតត្រឹមដំណាច់ឆ្នាំ ២០២៤, របបសន្តិសុខសង្គមមានចំនួន ៣ ធំៗ ដែលបានគ្របដណ្តប់លើពលរដ្ឋសរុបប្រមាណ **២,៧ លាននាក់**, ទាំងក្នុងវិស័យសាធារណៈ និង វិស័យឯកជន, ដោយបានចំណាយថវិកាសរុបចំនួនប្រមាណ **២ ២៩៧ ប៊ីលានរៀល**, ស្មើនឹងប្រមាណ **៥៧៤ លានដុល្លារអាម៉េរិក**, ក្នុងនោះ រួមមាន៖ ថវិការដ្ឋចំនួន **៤០៦ លានដុល្លារអាម៉េរិក** និង ថវិកាភាគទានប្រមាណ **១៦៨ លានដុល្លារអាម៉េរិក** ក្នុងមួយឆ្នាំ ដែលរបបសន្តិសុខសង្គមទាំងនោះរួមមាន៖ ១). **របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព** សម្រាប់កម្មករនិយោជិត, មន្ត្រីសាធារណៈ, អតីតមន្ត្រីរាជការ និង អតីតយុទ្ធជន, បុគ្គលស្វ័យនិយោជន៍ និង អ្នកក្នុងបន្ទុកសមាជិក ប.ស.ស.; ២). **របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ** សម្រាប់កម្មករនិយោជិត និង មន្ត្រីសាធារណៈ; និង ៣). **របបសន្តិសុខសង្គមផ្នែកប្រាក់សោធន** សម្រាប់កម្មករនិយោជិត, អតីតមន្ត្រីរាជការ និង អតីតយុទ្ធជន ។

លើសពីនេះ, នៅពេលជួបវិបត្តិ និង គ្រោះអាសន្នកន្លងមក, ទាំងការរីករាលដាលនៃជំងឺកូវីដ-១៩, សម្ពាធអតិផរណា និង គ្រោះទឹកជំនន់ធ្ងន់ធ្ងរ, រាជរដ្ឋាភិបាល ក៏បានគិតគូរ និងផ្តល់ការគាំពារដល់ពលរដ្ឋ តាមរយៈអន្តរាគមន៍ជំនួយសង្គមពិសេស ដល់គ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ដោយបានចំណាយថវិការដ្ឋបន្ថែមសរុបចំនួន **៥, ៧ ទ្រីលានរៀល**, សមមូលប្រមាណ **១ ៤២២ លានដុល្លារអាម៉េរិក**, ដើម្បីជួយរក្សាលំនឹងជីវភាព, កាត់បន្ថយកម្មវិបាកអវិជ្ជមាន និង ស្តារជីវភាពរបស់ពលរដ្ឋ ប្រកបដោយប្រសិទ្ធភាព ។

ជារួម, ចាប់តាំងពីការចាប់ផ្តើមអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០១៦- ២០២៥, ប្រព័ន្ធគាំពារសង្គមកម្ពុជា ត្រូវបានពង្រីកវិសាលភាពលើសមុន **ជាង ២ ដង** ខណៈការគ្របដណ្តប់ប្រជាពលរដ្ឋ បានកើនពីចំនួន **៣,៣ លាននាក់** កាលពីឆ្នាំ ២០១៧ ដល់ជាង **៧,៥ លាននាក់** ក្នុងឆ្នាំ ២០២៤ ។

- **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី, ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត;**
- **អង្គពិធីទាំងមូល ជាទីមេត្រី!**

នៅដំណាក់កាលបន្ទាប់, ក្នុងគោលបំណងធានានិរន្តរភាពនៃការបន្តតម្រង់ទិសការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា ឲ្យកាន់តែរឹងមាំ និង ប្រសើរ សម្រាប់រយៈពេល ១១ ឆ្នាំបន្តទៀត, ក្រុមប្រឹក្សាជាតិគាំពារសង្គម បានរៀបចំធ្វើបច្ចុប្បន្នកម្ម **ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ ២០១៦-២០២៥** ឲ្យទៅជា **ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ ២០២៤-២០៣៥** ដោយបានបញ្ចូលនូវលទ្ធផលនៃការវាយតម្លៃពាក់កណ្តាលអាណត្តិ នៃ

ការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ ២០១៦-២០២៥ និង ធាតុចូល ដែលទទួលបានពីក្រសួង-ស្ថាប័ន, ដៃគូអភិវឌ្ឍន៍, តំណាងនិយោជក និង និយោជិត, អង្គការសង្គមស៊ីវិល និង ភាគីពាក់ព័ន្ធ តាមរយៈកិច្ចប្រជុំបច្ចេកទេស, កិច្ចប្រជុំពិគ្រោះយោបល់ និង សិក្ខាសាលាពិគ្រោះយោបល់សាធារណៈ ជាច្រើនលើក ។

ខ្ញុំសូមគូសបញ្ជាក់ម្តងទៀតថា **ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ដំណាក់-កាលថ្មីនេះ** បានធ្វើការផ្លាស់ប្តូរ ពីអភិក្រមនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម តាមបែបសសរស្តម្ភ ទៅជាការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម និង ការផ្តល់កិច្ចគាំពារ តាមហានិភ័យនៃវដ្តជីវិត ទាំង ៧ រួមមាន៖ មាតុភាព និង ហានិភ័យកុមារភាព, ហានិភ័យសុខភាព, ហានិភ័យការងារ, ពិការភាព, និកម្មភាព, ភាពគ្មានជម្រក, និង ជរាភាព និង ឧត្តរជីវី ដោយកំណត់នូវទិសដៅអន្តរាគមន៍ គាំពារសង្គម តាមដំណាក់កាលនីមួយៗ ក៏ដូចជា កំណត់វិធានការគោលនយោបាយ សម្រាប់ កិច្ចការឆ្លងវិស័យពាក់ព័ន្ធ ដើម្បីជួយជំរុញដំណើរការអភិវឌ្ឍ និង ជានាមិនបង្កភាពរាំងស្ទះដល់ ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម, ទាំងដោយផ្ទាល់ និង ដោយប្រយោល ។

ខ្ញុំសូមអនុញ្ញាតយកឱកាសនេះ សម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ជូនក្រសួង-ស្ថាប័នពាក់ព័ន្ធ នៃរាជរដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៍ និង ភាគីពាក់ព័ន្ធទាំងអស់ ដែលបានយកចិត្តទុកដាក់ និង ផ្តល់កិច្ចសហការយ៉ាងល្អ ក្នុងការរៀបចំ **ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ ២០២៤-២០៣៥** ដែល **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** នឹងប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ ក្នុងពេលបន្តិចទៀតនេះ ។

- សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត;
- អង្គពិធីទាំងមូល ជាទីមេត្រី!

ក្នុងនាមជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម និង ក្នុងនាមពលរដ្ឋកម្ពុជាទាំងអស់, ខ្ញុំសូមសម្តែងនូវការរម្លឹកដឹងគុណដ៏ជ្រាលជ្រៅបំផុត គោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, **អតីតនាយករដ្ឋមន្ត្រី និង បច្ចុប្បន្នជាប្រធានព្រឹទ្ធសភា,** ដោយបានផ្តួចផ្តើម, ដឹកនាំ, និង ជំរុញអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា ប្រកបដោយភាពមធ្យ័ត, ជវភាព, និង ចក្ខុវិស័យវែងឆ្ងាយ ។ ជាមួយនេះ, ខ្ញុំក៏សូមសម្តែងនូវការដឹងគុណដ៏ខ្ពង់ខ្ពស់ ជូន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែល បានលះបង់នូវកម្លាំងកាយ-ចិត្ត និង ប្រាជ្ញា-ស្មារតី ក្នុងការបន្តវេនដឹកនាំប្រទេស ដោយបន្ត យកចិត្តទុកដាក់ខ្ពស់ លើសុខុមាលភាព និង វិបុលភាពរបស់ពលរដ្ឋ និង បានតាំងចិត្តយ៉ាង

មោះមុត ក្នុងការបន្តជំរុញអភិវឌ្ឍ **«នាវាគាំពារសង្គមកម្ពុជា»** ឲ្យកាន់តែរឹងមាំ និង បន្តដំណើរទៅមុខ ប្រកបដោយនិរន្តរភាព ឈានឆ្ពោះទៅសម្រេចបាននូវ **ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០** ក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាព នៅពេញផ្ទៃប្រទេស ។

ក្នុងនាមជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម, ខ្ញុំក៏សូមប្តេជ្ញាសហកាជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីបន្តកសាង និង កែទម្រង់ប្រព័ន្ធគាំពារសង្គម ដើម្បីពង្រីកការគ្របដណ្តប់ ឲ្យបានកាន់តែប្រសើរ ជាប្រយោជន៍សម្រាប់ពលរដ្ឋកម្ពុជាគ្រប់រូប ។ បន្ថែមលើនេះ, ក្នុងនាមជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ខ្ញុំនឹងបន្តខិតខំពង្រឹងការប្រមូលចំណូល, ពង្រឹងប្រសិទ្ធភាពចំណាយ, បង្កើនលំហសារពើពន្ធ, និង បង្កើនការសន្សំសំចៃថវិកាជាតិ សំដៅបម្រើដល់គោលនយោបាយទាំងឡាយរបស់រាជរដ្ឋាភិបាល រួមបញ្ចូលផងដែរនូវ **ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ក្នុងដំណាក់កាលថ្មីនេះ** ដើម្បីពង្រីកការ-គ្របដណ្តប់ឲ្យកាន់តែប្រសើរ ទៅតាមហានិភ័យនៃវដ្តជីវិត ។

មុននឹងបញ្ចប់, ជាថ្មីម្តងទៀត, ខ្ញុំសូមគោរពថ្លៃងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូន **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** ដែលបានផ្តល់កិត្តិយសដ៏ឧត្តុង្គឧត្តមអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធី «**បើកសប្តាហ៍គាំពារសង្គមកម្ពុជា ឆ្នាំ ២០២៥ និង ប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ នូវ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ ២០២៤-២០៣៥**» នាថ្ងៃនេះ និង សូមគោរពជូនពរ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី**, ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, សមាជិក-សមាជិកានៃអង្គពិធីទាំងមូល បានសមប្រកបនឹងពុទ្ធពរទាំង ៤ ប្រការ គឺ៖ **អាយុ, វណ្ណៈ, សុខៈ និង ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

ជាកិច្ចបន្ត, ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់, ខ្ញុំសូមអនុញ្ញាតគោរពអញ្ជើញ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាថ្លែងសុន្ទរកថាគន្លឹះ និង ផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ ជូនអង្គពិធីទាំងមូល ។

សូមគោរពអញ្ជើញ !